ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ELECTRICITE DU CAMBODGE

អគ្គិសនីកម្ពុជា

លេខ : ០៤៧ សសរ.ររក.១ប

# សេចក្តីសម្រេច
## ស្តីពី
## ការជ្រើសរើស កម្មករអណ្តែត

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

- បានឃើញ ព្រះរាជក្រឹត្យ ជស/រកត/០៣៩៦/១០ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអគ្គិសនីកម្ពុជា ជាក្រុមហ៊ុនទទួលខុសត្រូវមានកំណត់មួយរបស់រដ្ឋ
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/០៨០៨/៩៨៧ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ ស្តីពីការតែងតាំង ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា
- យោងតាម លិខិតលេខ ៤៩០ ផសជ / ២០១៤ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤ របស់ការិយាល័យផ្គត់ផ្គង់សម្ភារ និងដឹកជញ្ជូន នៃនាយកដ្ឋានលទ្ធកម្ម
- យោងតាម កំណត់ហេតុ នាថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥ របស់គណៈកម្មការជ្រើសរើសនិយោជិតកម្មករ ស្តីពី ការប្រឡងជ្រើសរើសនិយោជិតសរុបចំនួន ១៥ រូប សម្រាប់បណ្តាការិយាល័យ-អង្គភាព នៃអគ្គិសនីកម្ពុជា

## សម្រេច

**ប្រការ១** : ជ្រើសរើសកម្មករអណ្តែត ចំនួន ០២ រូប ឱ្យចូលបម្រើការងារជាកម្មករឃ្លាំងចំការដូង នៅការិយាល័យ ផ្គត់ផ្គង់សម្ភារនិងដឹកជញ្ជូន នៃនាយកដ្ឋានលទ្ធកម្ម ចាប់ពីថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៥ តទៅ ដូចមាន រាយនាមខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១-លោក | ហេង ពិសិដ្ឋ | កើតថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៩៤ | កម្រិតវប្បធម៌ | Bacc II |
| ២-លោក | ពៅ បូរិន | កើតថ្ងៃទី០៨ ខែមិថុនា ឆ្នាំ១៩៩៤ | -"- | -"- |

**ប្រការ២** : សាមីជន ដូចមានចែងក្នុងប្រការ១ :

-ត្រូវចូលបម្រើការងារ និងទទួលប្រាក់កម្រៃពលកម្មប្រចាំថ្ងៃ តាមខ្លឹមសារ ដូចមានចែងក្នុងកិច្ចសន្យា ការងាររយៈពេល ០៦ ខែ ដែលបានព្រមព្រៀងគ្នា រវាងសាមីខ្លួន និងអគ្គិសនីកម្ពុជា ។

-និងត្រូវបញ្ឈប់ពីការងារ ពីអគ្គិសនីកម្ពុជា នៅពេលផុតកំណត់នៃកិច្ចសន្យា ។

**ប្រការ៣** : នាយករដ្ឋបាល នាយកហិរញ្ញកិច្ច-គណនេយ្យ នាយកលទ្ធកម្ម ប្រធានការិយាល័យផ្គត់ផ្គង់សម្ភារ និងដឹកជញ្ជូន ព្រមទាំងសាមីខ្លួន ត្រូវអនុវត្តក្នុងក្របខ័ណ្ឌភារកិច្ចរៀងៗខ្លួន តាមខ្លឹមសារនៃ សេចក្តីសម្រេចនេះ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៥

ELECTRICITE DU CAMBODGE

កែវ រតនៈ

**ចម្លងជូន**

- អគ្គនាយករង អគ្គិសនីកម្ពុជា
- ដូចប្រការ ៣
- ឯកសារ - កាលប្បវត្តិ